អត្ថបទ ធម៌ទេសនា

ស្ដីអំពី

# “ទាន”

ភិក្ខុ កែវ-អ៊ុន ឬ សំអៀន

“ អភិញ្ញានសីលោ ”

វត្ត **សម្ដេចព្រះមហាឃោសានន្ទ**

“មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរអន្តរជាតិ”

ទីក្រុងអូកឡិនដ៍ រដ្ឋកាលីហ្វ័រនីញ៉ា

សហរដ្ឋ អាមេរិក

ពុធ១៥កើតផល្គុន,ឆ្នាំម្សាញ់បញ្ចស័ក ព.ស.២៥៥៦; ទី៥មេសា គ.ស.២០១៣

សូមលោកអ្នក មេត្តានឹកឈ្មោះខ្ញុំ,ហើយឧទ្ទិសកុសលឲ្យដល់ខ្ញុំផង!

## អត្ថបទស្តី អំពីទាន

ទាន!ជាភាសាបាលីប្រែៈ"ឱយ!ឬធ្វើអំណោយ!" បើតាមអត្ថន័យនៃពាក្យនេះ គឺជាការចែកសេចក្តីសុខដល់អ្នកទទួល!ដូច្នេះអ្នកឲ្យត្រូវឲ្យវត្ថុដែលគួរឲ្យហើយឲ្យដល់មនុស្សដែលគួរឲ្យទៀត។វត្ថុដែលគួរឲ្យបានដល់របស់ណាដែលអ្នកទទួលយកទៅប្រើប្រាស់បានក្នុងផ្លូវដែលមិនខុសដូចជាបាយសម្ល នំចំណី សំលៀកបំពាក់ ផ្លែឈើ ឬថ្នាំកែរោគជាដើម។ ឯមនុស្សដែលគួរឲ្យនោះ បានដល់មនុស្សដែលទីទ័លក្រ ឬខ្វាក់ខ្វិន,ជរា,ពិការ ជាដើម. ប៉ុន្តែសូមកុំភ្លេចថាការធ្វើបុណ្យអ្វីផ្សេងៗក៏រាប់ថាជាទានដែរ ដូចជាបុណ្យ"កឋិន"ជាដើម.ដែលបុព្វបុរសរបស់យើងលោកបានភ្ជាប់ពាក្យទាំងពីរនេះរួមចូលជាមួយគ្នាផងថាបុណ្យ"កឋិនទាន"ដូច្នេះការឲ្យទានឬការធ្វើទាននេះ ជាបវេណីកិច្ចដ៏ប្រសើររបស់កល្យាណជនឬសប្បុរសជន បើពោលឲ្យខ្ពស់ជាងនេះទៀត ជាចរិយាដ៏វិសេស! របស់បណ្ឌិតទាំងឡាយ!មានព្រះពោធិសត្វ ជាដើមដែលលោកតែងតែបំពេញទុកជាឧបនិស្ស័យនៃការត្រាស់ដឹងជារៀងរាល់ជាតិមិនដែលរំលងឡើយ។ ផលកម្រៃនៃការឲ្យទាននេះរមែងនាំបណ្តាលឲ្យបានសម្រេចប្រយោជន៍គឺសេចក្តីល្អសេចក្តីសុខចំរើនដល់បុគ្គលអ្នកធ្វើនោះៗ ជាច្រើនប្រការ ។ សូម្បីមានអស់លោកខ្លះ ដែលមានចិត្តប្រកបដោយទុទិដ្ឋិនិយមខ្លាំងពេកទៅបានពោលថា"ការឲ្យឬការធ្វើទាននេះ វានាំឲ្យតែអស់ទ្រព្យសម្បត្តិហ្នឹង!!" ទោះបីមានអ្នកខ្លះពោលដូច្នេះក៏ពិតមែន ប៉ុន្តែ បើយើងគិតឲ្យជ្រៅជាងនេះបន្តិចទៅ ជា"សុទិដ្ឋិនិយម" វិញនោះ យើងនឹងបានឃើញច្បាស់ថាៈ បើយើងលះបង់ទ្រព្យសម្បត្តិធ្វើជាទានអស់ចំនួនប៉ុនណា? ឯមច្ឆរិយៈកិលេស គឺសេចក្តីកំណាញ់ ដែលមាននៅក្នុងសន្តានចិត្តរបស់យើង ក៏វានឹងជ្រះស្រឡះចេញពីសន្តានចិត្តរបស់យើងក៏មានចំនួនប៉ុណ្ណោះដែរ!ហើយយើងបានមកវិញនូវ អរិយទ្រព្យ ដ៏ប្រសើរៈសេចក្តីល្អជាបុណ្យកុសល

ដែលកប់ទុកក្នុងសន្តានចិត្តរបស់យើងឯណោះ នេះឯងជារឿងសំខាន់បំផុតនោះ,រួចបុណ្យកុសលដែលដម្កល់ទុកក្នុងសន្តានចិត្តរបស់យើងនេះឯងសម្រាប់ជាស្បៀងទៅក្នុងអនាគតជាតិឯណោះទៀត,នែ!ត្រូវយល់ឲ្យច្បាស់អញ្ចឹង,ប៉ុន្តែការឲ្យទាននេះជាកិច្ចដែលបុគ្គលនឹងធ្វើឲ្យល្អបរិសុទ្ធគ្រប់គ្រាន់បានដោយកម្រជាងការកាន់សីល ព្រោះការកាន់សីលបើបុគ្គលត្រូវការកាន់គ្រាន់តែរៀនឲ្យចេះសិក្ខាបទទាំង៥ ហើយឲ្យដឹងពីកិច្ចដែលត្រូវតមត្រូវវៀរប៉ុណ្ណោះជាដើម ហើយសមាទានកាន់យកអំពីសំណាក់ភិក្ខុ ឬ សាមណេរជាដើម យកមកខំប្រព្រឹត្តប្រតិបត្តិសង្រួមឲ្យបានត្រឹមត្រូវល្អតាមច្បាប់នោះប៉ុណ្ណោះ ក៏អាចញ៉ាំងកុសលនោះៗឲ្យបានល្អបរិសុទ្ធបានហើយ! រួចសីលនេះបុគ្គល,ទាំងអ្នកមានទាំងអ្នកក្រ,ទាំងស្តេច,មន្ត្រី,សេដ្ឋី,គហបតី,ពាណិជករ,កសិករ,កម្មករអីក៏អាចធ្វើបានដូចគ្នាព្រោះសីលជាកុសលដែលបុគ្គលត្រូវរក្សាដោយវិរតិចេតនាម្នាក់ៗបានមិនបាច់ដាច់បង់ទ្រព្យសម្បត្តិអ្វីច្រើនឡើយ!នែ!សីលវាងាយធ្វើជាងការធ្វើទានអញ្ចឹង!។ឯការធ្វើទាននោះវិញ លុះតែបុគ្គលមានទេយ្យវត្ថុគ្រប់គ្រាន់ល្មមលះធ្វើកើតផងទាំងបដិគ្គាហកៈអ្នកទទួលក៏មានផង ហើយមានចេតនាដ៏មុតមាំក្នុងការលះធ្វើផង ទើបធ្វើកើតទៅជាទានបាន!។ រួចវេលាដែលធ្វើនោះទៀតសោត មានកិច្ចត្រូវខ្វល់ខ្វាយក៏ច្រើនទៀត។ ទានក្នុងព្រះពុទ្ធសាសនាបុគ្គលត្រូវចាត់ចែងធ្វើឲ្យត្រឹមត្រូវតាមប្រពៃណី! តាមពុទ្ធានុញ្ញាតិទៀតផង! ទើបនឹងបានផលានិសង្សច្រើនពេញលេញតាមបំណង!បើនឹងចេះតែធ្វើបំពានទាំងខ្ជីខ្ជាដោយការមិនចេះមិនដឹង ដោយអាងសក្តិយស ឬអាងមានទ្រព្យសម្បត្តិច្រើនធ្វើតាមទំនើងចិត្តចង់ដោយញាណវិប្បយុត្ត មិនអាស្រ័យច្បាប់ព្រះពុទ្ធសាសនាដែលមានមកក្នុងគម្ពីរដីកាជាគោលផងទេនោះទាននោះមិនបានឈ្មោះថាធ្វើដោយប្រពៃឡើយទាំងផលនៃទាននោះក៏ខ្សោយចុះមកជាលំដាប់ដែរ រីឯរបស់ដែលគួរជាវត្ថុទានទៀតសោត

បើមិនបានប្រណីតជាងរបស់ដែលខ្លួនប្រើប្រាស់រាល់ថ្ងៃទេ! ,កុំឲ្យតែទាបជាង! រួចប្រសិនបើយករបស់ដែលបានមកពីការកេងប្រវ័ញ្ចគេឬបានមកពីអំពើទុច្ចរិតអ្វីផ្សេងៗទៀតហើយយកមកធ្វើទាននោះរបស់នោះមិនសមជាវត្ថុទានឡើយ ព្រោះ វាមិនមែនជា "ធម្មលទ្ធវត្ថុទាន" វត្ថុមិនបានប្រកបដោយធម៌។ មានព្រះពុទ្ធដីកាមួយកន្លែងក្នុង "ទក្ខិណាវិភង្គសូត្រ" សំដែងអំពីទក្ខិណាវិសុទ្ធិ ៤យ៉ាងថាៈ ១- **ទាយកោ វិសុជ្ឈតិ នោ បដិគ្គាហកោ** ទានបរិសុទ្ធពីអ្នកឲ្យមិនបរិសុទ្ធអំពីអ្នកទទួលគឺអ្នកឲ្យមានសីលបរិសុទ្ធមានធម៌ល្អ, ឯអ្នកទទួលទ្រុស្តសីលមានធម៌មិនល្អ!។ ២- **បដិគ្គាហកោ វិសុជ្ឈតិ នោ ទាយកោ** ទានបរិសុទ្ធពីអ្នកទទួល មិនបរិសុទ្ធពីអ្នកឲ្យ គឺអ្នកឲ្យទ្រុស្តសីលមានធម៌មិនល្អ,អ្នកទទួលមានសីលបរិសុទ្ធមានធម៌ល្អ!។ ៣- **នេវ ទាយកោ វិសុជ្ឈតិ នោ បដិគ្គាហកោ** ទានមិនបរិសុទ្ធពីអ្នកឲ្យផង មិនបរិសុទ្ធពីអ្នកទទួលផង គឺអ្នកឲ្យទ្រុស្តសីលមានធម៌មិនល្អ អ្នកទទួលក៏ទ្រុស្តសីលមានធម៌មិនល្អដូចគ្នា។ ៤- **ទាយកោ ចេវ វិសុជ្ឈតិ បដិគ្គាហកោ ច** ទានបរិសុទ្ធអំពីអ្នកឲ្យផង,បរិសុទ្ធអំពីអ្នកទទួលផង គឺអ្នកឲ្យមានសីលបរិសុទ្ធមានធម៌ល្អ,ឯអ្នកទទួលក៏មានសីលបរិសុទ្ធមានធម៌ល្អដូចគ្នាទាំងពីរខាង។ លក្ខណៈ នៃការឲ្យទានមានបទបែបពិសេសយ៉ាងហ្នឹង!ហើយលក្ខណៈទី៤នេះកម្ររកបានផង!។ អាស្រ័យហេតុនេះបានជាបណ្ឌិតលោកពោលថា ទាននេះជាកិច្ចដែលបុគ្គលកម្រធ្វើបានដោយល្អប្រពៃណាស់គឺលុះណាតែប្រកបដោយអង្គ៦ប្រការទើបជាទានមានផលានិសង្សច្រើន!។ អង្គខាងអ្នកឲ្យមាន៣ប្រការនោះគឺ ១- **បុព្វេវ ទានា សុមនោ ហោតិ** អ្នកឲ្យមានចិត្តត្រេកអរក្នុងពេលមុនឲ្យហៅថា បុព្វចេតនា។ ២- **ទទំ ចិត្តំ បសាទេតិ** អ្នកឲ្យញុំាងចិត្តជ្រះថ្លាក្នុងពេលកំពុងឲ្យ ហៅថាមុញ្ចនចេតនា។ ៤-**ទត្វា អត្តមនោ ហោតិ** អ្នកឲ្យមានចិត្តត្រេកអរថែមតាមទានដែលខ្លួនបានឲ្យរួចហើយទោះឲ្យក្នុង

ពេលថ្មីៗនេះក្តីឲ្យយូរហើយក្តីនឹកឃើញពេលណា ?ត្រេកអរពេលណា
បានបុណ្យពេលនោះហៅថាអបរាបរចេតនា។ អង្គអ្នកទទួលក៏មាន៣
១- **វីតរាគា ហោន្តិ រាគវិនយាយ វា បដិបន្នា** បដិគ្គាហកៈអ្នកទទួល
ទានអស់រាគៈពីសន្តានចិត្តហើយឬកំពុងប្រតិបត្តិ ដើម្បីកំចាត់បង់រាគៈ
២- **វីតទោសា ហោន្តិ ទោសវិនយាយ វា បដិបន្នា** បដិគ្គាហកៈអ្នក
ទទួលទានអស់ទោសៈពីសន្តានចិត្តហើយឬកំពុងប្រតិបត្តិដើម្បីកំចាត់
បង់នូវទោសៈ ។ ៣- **វីតមោហា ហោន្តិ មោហវិនយាយ វា បដិបន្នា**
បដិគ្គាហកៈអ្នកទទួលទានអស់មោហៈពីសន្តានចិត្តហើយឬកំពុងប្រតិ
ប្រតិបត្តិដើម្បីកំចាត់បង់នូវមោហៈ។ ទានដែលប្រកបដោយអង្គ៦ប្រ -
ការនេះ,ព្រះសម្ពុទ្ធទ្រង់សរសើរថាទានមានផលានិសង្សច្រើនណាស់!
បុគ្គលមិនអាចនឹងគណនារាប់ថាមានចំនួនប៉ុណ្ណេះប៉ុណ្ណោះបានឡើយ
ដូចជាមានរឿងពិត,ក្នុងសម័យដែលអង្គព្រះសម្ពុទ្ធទ្រង់គង់ធរមាននៅ
ទាំងអង្គអរហន្តសាវ័កក៏នៅមានច្រើនព្រះអង្គផង,ជំនាន់នោះបុគ្គលធ្វើ
ទានបានផលជាក់ស្តែងទាន់ភ្នែកច្រើណាស់! ព្រោះថាអ្នកឲ្យទានមាន
កិលេសស្រាលស្តើងណាស់រួចមានចិត្តជ្រះថ្លាខ្ពស់សមនឹងបដិគ្គាហក
:អ្នកទទួលទាននោះសុទ្ធតែជាព្រះអរហន្តផង។ដូចមានរឿងដំណាល
ក្នុងគម្ពីរធម្មបទជាច្រើនដូចជារឿងដែលយើងធ្លាប់បានចេះចាំ! ខ្លះមក
ហើយដូចរឿងទុគ៌តបុរសថាបានថ្វាយចង្ហាន់បិណ្ឌបាត្រចំពោះព្រះពុទ្ធ
រួចបានឡើងឋានៈជាមហាសេដ្ឋីជាដើម។ខ្ញុំលើករឿងនេះមកជំរាបជូន
អស់លោកអ្នកស្តាប់ពិចារណាដូចតទៅនេះ, ទុគ៌តបុរសជាមនុស្សអ្នក
ក្រណាស់, កំសត់ណាស់! ក្របំផុត!កាលពីជំនាន់ព្រះ! ថានៅថ្ងៃមួយ
មានបុរសអ្នកចាត់ចែងភត្តប្រគេនព្រះភិក្ខុសង្ឃម្នាក់បានដើរបបួលអ្នក
ស្រុកគ្រប់គ្នាឲ្យទទួលយកព្រះសង្ឃតាមសទ្ធារៀងខ្លួនដើម្បីរៀបចំភត្ត
ថ្វាយប្រគេនព្រះភិក្ខុសង្ឃដែលមានព្រះពុទ្ធជាព្រះប្រធាន,គាត់បបួល
តាំងពីផ្ទះសេដ្ឋីអនុសេដ្ឋីនិងអ្នកស្រុកធម្មតាជាហូរហែមកអ្នកខ្លះទទួល

ព្រះសង្ឃ៥អង្គ,ខ្លះ១០អង្គ,ខ្លះ២០អង្គជាដើម..បុរសអ្នកចាត់ចែងភត្ត ក៏បានកត់ត្រាឈ្មោះអ្នកម្ចាស់ទាននិងចំនួនព្រះសង្ឃតាមដែលគេបាន ទទួលនោះៗជាបន្តបន្ទាប់រហូតមកលុះមកដល់ផ្ទះទុគ៌តបុរសៗក៏បាន ទទួលព្រះសង្ឃ១អង្គនឹងគេដែរ,ប៉ុន្តែបុរសអ្នកចាត់ចែងភត្តមិនបានជា កត់ឈ្មោះទុគ៌តបុរសផងទេមើលទៅ! ប្រហែលជាគិតថា ១អង្គមិនចាំ បាច់កត់ឈ្មោះអីទេ។ លុះវេលាភត្តកាលដល់ហើយបុរសអ្នកចាត់ចែង ភត្តក៏បានប្រគល់ព្រះសង្ឃដល់ម្ចាស់ទានតាមចំនួនរបស់គេជាលំដាប់ លំដោយគ្រប់ៗគ្នាទាំងអស់ជាហូរហែមករហូតដល់អស់ព្រះសង្ឃ លុះ ទុគ៌តបុរសទៅសុំព្រះសង្ឃ, ទើបបុរសអ្នកចាត់ចែងភត្តភ្ញាក់ខ្លួនព្រើត! រួចក៏ពោលថា“ឱ!សំឡាញ់!ខ្ញុំសុំអភ័យទោសៗខ្ញុំភ្លេចឈឹងទៅហើយ ប៉ុន្តែណ្ហើយចុះ!ៗសុំសំឡាញ់កុំទាន់អស់សង្ឃឹមពីព្រោះឥឡូវនេះព្រះ ពុទ្ធព្រះអង្គមិនទាន់ស្តេចយាងចេញពីព្រះគន្ធកុដិនៅឡើយទេ! ដូច្នេះ សុំសំឡាញ់សាកល្បងទៅនិមន្តព្រះអង្គដោយផ្ទាល់តែម្តងទៅ! ក្រែង ព្រះអង្គស្តេចទ្រង់អនុគ្រោះ!។ ទុគ៌តបុរសឮដូច្នោះ!ឥតមានគិតបារម្ភ ញញើតញញើមអ្វីឡើយ! ថែមទាំងមានសេចក្តីរីករាយជាខ្លាំងទៅវិញ, ដោយគិតថាបានទៅនិមន្តព្រះពុទ្ធដោយផ្ទាល់!ហើយក៏ដើរដម្រង់ឆ្ពោះ ទៅរកព្រះគន្ធកុដិតែម្តងរួចមានសេដ្ឋីៗជាច្រើននៅជិតព្រះគន្ធកុដិនោះ រង់ចាំទទួលយាងព្រះពុទ្ធ។ រីឯព្រះពុទ្ធគ្រាន់តែទុគ៌តបុរសដើរទៅដល់ ជណ្តើរព្រះគន្ធកុដិនោះ, ព្រះអង្គក៏បើកទ្វារព្រះគន្ធកុដិយាងចេញមក ហើយបានប្រទានបាត្រដល់ដៃទុគ៌តបុរសភ្លាម, ឯទុគ៌តបុរសកាលបើ បានទទួលបាត្រអំពីព្រះពុទ្ធភ្លាមហើយក៏ត្រេកអរស្ទើរហោះស្ទើរលោត កញ្ឆោង!សូម្បីពួកសេដ្ឋីៗដែលនៅក្បែរៗនោះ គេអង្វរសុំបាត្រពីទុគ៌ត បុរស ដោយគេនិយាយថាៈនឹងជូនប្រាក់រាប់ពាន់រាប់ម៉ឺនគហាបណៈក៏ ទុគ៌តបុរសមិនរវល់មិនអើពើគាត់គិតតែពីយាងព្រះពុទ្ធទាល់តែដល់ផ្ទះ រស់ខ្លួន,និយាយពីផ្ទះរបស់ទុគ៌តបុរស បើតាមធម្មតាអ្នកដែលត្រូវចេញ

ចូលផ្ទះនោះលុះតែដើរឱនទើបបាន! , ប៉ុន្តែចំពោះព្រះពុទ្ធស្តេចយាង ចូលតាមធម្មតាព្រះអង្គឥតបានឱនព្រះកាយអ្វីបន្តិចបន្តួចសោះឡើយ ព្រោះអ្វី? ពីព្រោះវិស្សកម្មទេវបុត្តបានទៅនិមិត្តរៀបចំថ្វាយទុកជាមុនស្រេច! រួចមានទេវបុត្ត-ធីតាបាននាំយកឱជារសដ៏ជាទិព្វ!ទៅដាក់ក្នុងចង្ហាន់ដែលទុគ៌តបុរសបានរៀបចំទុកថ្វាយព្រះពុទ្ធនោះថែមទៀត! ។ លុះទុគ៌តបុរស!បានថ្វាយចង្ហាន់ចំពោះព្រះពុទ្ធ ដោយគោរពនិងដ៏ផ្ចិតផ្ចង់ចប់សព្វគ្រប់ហើយព្រះពុទ្ធក៏ស្តេចទ្រង់ប្រទានភត្តានុមោទនាញ៉ាំងចិត្តទុគ៌តបុរស! និងភរិយាឲ្យមានបីតិសោមនស្សរីករាយជ្រះថ្លាយ៉ាងក្រៃលែងថែមទៀត។ រួចទុគ៌តបុរសទទួលបាត្រពីព្រះពុទ្ធហើយលើកស្ពាយបាត្រដើរតាមថ្វាយព្រះរាជដំណើរព្រះពុទ្ធ រហូតដល់ទៅព្រះគន្ធកុដិ(កាលជំនាន់នោះទាំងព្រះពុទ្ធទាំងព្រះសង្ឃពុំមានប្រើចានស្រាក់) ដូចពួកយើងទេ បើមានចង្ហាន់ប៉ុន្មានគេដាក់ចូលក្នុងបាត្រទាំងអស់តែម្តង។ពេលដែលទុគ៌តបុរសថ្វាយបាត្រទៅព្រះពុទ្ធរួចហើយក៏ថ្វាយបង្គំព្រះអង្គវិលត្រឡប់មកផ្ទះវិញ លុះត្រឡប់មកដល់ផ្ទះក៏ស្រាប់តែឃើញមានទ្រព្យសម្បត្តិ ប្រាក់មាសពេជ្រកើតមានពេញផ្ទះគរពូនហូរហៀរ។ ដំណឹងនេះក៏បានឮជ្រួតជ្រាបពេញស្រុករហូតដល់ព្រះមហាក្សត្រ,ព្រះរាជាស្តេចអស្ចារ្យក្នុងព្រះទ័យដ៏ខ្លាំង ក៏បានតែងតាំងទុគ៌តបុរសឲ្យមានឋានៈជាមហាសេដ្ឋីតាំងពីពេលនោះមក។នែ!ការថ្វាយទានចំពោះព្រះពុទ្ធដោយផ្ទាល់ដ៏ប្រកបដោយអង្គគឺវាបានផលជាក់ស្តែងអញ្ចឹងវាមានការអស្ចារ្យយ៉ាងហ្នឹង!។ មានរឿងមួយទៀត និយាយអំពីព្រាហ្មណ៍ដ៏កំសត់ម្នាក់ក្រខ្សត់ណាស់ដែរ,ពីរនាក់ប្តីប្រពន្ធមានសំពត់បង់កតែ១, បើម្នាក់ត្រូវការធ្វើដំណើរទៅណាម្នាក់ទៀតត្រូវតែខាន,នៅយប់មួយនោះព្រាហ្មណ៍ជាស្វាមីបានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះពុទ្ធយើងជាមួយអ្នកស្រុកភូមិជាច្រើនដែលមានព្រះមហាក្សត្រព្រះបាទបសេនទិ-កោសលស្តេចយាងទៅដែរដោយធម៌ទេសនានោះព្រះពុទ្ធទ្រង់សំដែង

លៃឲ្យល្មមដល់សន្ដានចិត្តជាឧបនិស្ស័យរបស់គាត់ៗ ព្រាហ្មណ៍នោះ ស្ដាប់ទៅពិរោះខ្លាំងណាស់គាត់ចង់បូជាព្រះធម៌ដោយវត្ថុអ្វីមួយឱ្យសម ល្មមនឹងទំហំទឹកចិត្តដែលគាត់ជ្រះថ្លា ប៉ុន្តែមិនមានរបស់អ្វីឱ្យសមល្មម នឹងការបូជាសោះក្រៅពីសំពត់បង់កនោះម្ល៉ោះហើយចិត្តរបស់គាត់ចេះ តែស្ទាក់ស្ទើរ“ម្ដងកាត់ចិត្តឡើងថាបូជាម្ដងដកថយៗៗ ”ដោយគិតថា ប្រសិនបើអញយកសំពត់បង់កនេះបូជាព្រះធម៌ទៅខ្លួនរបស់អាត្មាអញ ជាប្រុសមិនអីទេ!ប៉ុន្តែភរិយារបស់អាត្មាអញជាស្រីមុខជាអត់អ្វីដណ្ដប់ ម្ល៉ោះហើយគ្នាមិនអាចចេញក្រៅផ្ទះបានឡើយចិត្តស្ទាក់ស្ទើររបស់គាត់ បែបនេះតាំងពីក្បាលព្រលប់រហូតដល់ពេលបច្ឆិមយាមនៃរាត្រី( ជិតភ្លឺ )ទើបចិត្តជ្រះថ្លារបស់គាត់ឡើងដល់ថ្នាក់កំពូលជម្នះ លើចិត្តកំណាញ់ បានទើបគាត់ផ្ទុះជាសម្រែកយ៉ាងខ្លាំងឡើងថា “ ជិតំ មេៗ! អញ់ឈ្នះ-ហើយ!ៗ ”គឺឈ្នះលើចិត្តកំណាញ់របស់គាត់នោះឯង!រួចក៏យកសំពត់ បង់កបូជាព្រះធម៌ភ្លាមក្នុងពេលនោះទៅ, ឯមហាជនគេស្រឡាំងកាំង ឆ្ងល់គ្រប់ៗគ្នា!ទាំងព្រះរាជាបសេនទិកោសល ក៏ទ្រង់ឆ្ងល់ក្នុងព្រះទ័យ ខ្លាំងណាស់ដែរ! លុះព្រះរាជាស្ដេចសាកសួររឿងនោះ ទ្រង់បានជ្រាប សេចក្ដីអស់សព្វគ្រប់ទើបព្រះអង្គមានព្រះទ័យជ្រះថ្លានឹងចិត្តសទ្ធាជ្រះ ថ្លារបស់ព្រាហ្មណ៍នោះខ្លាំងណាស់! ដោយទ្រង់ព្រះចិន្ដាថា “ ឱ! ហ្ន៎! ព្រាហ្មណ៍នេះអស្ចារ្យណាស់ហ្ន៎! ហ៊ានបូជាព្រះធម៌ទាល់តែអស់របស់ ពីខ្លួន!ទើបទ្រង់បញ្ជារាជអាមាត្យឱ្យយកសំពត់ទាំងផាប់ៗព្រមទាំងវត្ថុ សម្ភារៈផ្សេងៗជាច្រើនព្រះរាជទានដល់ព្រាហ្មណ៍នោះយ៉ាងច្រើននៅ ពេលនោះ។ដោយអំណាចផលទានរបស់ព្រាហ្មណ៍នោះក្នុងគម្ពីរបាន បញ្ជាក់ថាក្រោយមកព្រាហ្មណ៍នោះមានទ្រព្យសម្បត្តិច្រើន ហូរហៀរ រហូតដល់ព្រះមហាក្សត្រតែងតាំងឱ្យមានឋានៈជាមហាសេដ្ឋីនៅថ្ងៃទី ៧ក្រោយពីបានបូជាសំពត់បង់កថ្វាយចំពោះព្រះពុទ្ធរួចមក។រឿងមួយ ទៀតថាៈមាននារីក្នុងត្រកូលអ្នកក្រីក្រ ដ៏កំសត់ម្នាក់បានដាក់បាត្រព្រះ

មហាកស្សបៈដោយ “លាជ”គម្ពីរបញ្ជាក់ថាបន្ទាប់ពីនាងដាក់បាត្ររួច ហើយនាងក៏ត្រូវស្លាប់ដោយសត្វអាសិរ្ពឹសខាំហើយនាងក៏បានទៅចាប់បដិសន្ធិកើតនៅនាឋានសួគ៌សុគតិឯណោះភ្លាម។ រឿងនេះគួរឱ្យយើងទាំងអស់គ្នាពិចារណាថា“លាជ”ជារបស់ធុនទាបបំផុតបើនៅស្រុកខ្មែរគេច្រើនតែនិយមសែនខ្មោចផង!។រួចបើនៅប្រទេសឥណ្ឌាក្នុងសម័យនោះតាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញខាងម្ហូបអាហារពិភពលោក!គេសន្និដ្ឋានថាៈលាជជាអាហារធុនអន់បំផុត! ជាអាហារដែលគេបរិភោគចម្លងពេលបណ្ដោះអាសន្នទេមិនមែនជាអាហារប្រចាំថ្ងៃឡើយ។ដូច្នេះនារីដែលបានទៅកើតជាទេពធីតាដ៏ស្រស់ប្រឹមប្រិយនោះឯងមិនមែនដោយសារតែលាជមួយមុខទេ គឺប្រាកដជាដោយសទ្ធាចិត្តជ្រះថ្លាដ៏ក្លាខ្លាំងមោះមុតក្នុងការធ្វើទានរបស់នាងនោះឯង!និងដោយសារបដិគ្គា-ហកៈអ្នកទទួលទាននោះគឺជាព្រះអរហន្តផង!។ ខ្ញុំលើករឿងទាំងនេះមកបង្ហាញឱ្យឃើញច្បាស់ថាៈទានដែលប្រកបដោយអង្គគឺវាបានផលប្រាកដជាក់ស្ដែងដូច្នេះឯង! ហើយរឿងទាំង៣នេះសុទ្ធតែបង្ហាញអំពីកម្លាំងទឹកចិត្ត, កម្លាំងផ្លូវចិត្តវាខ្លាំងជាងកម្លាំងអ្វីៗទាំងអស់យ៉ាងហ្នឹង! ឥឡូវនេះ យើងឆ្លុះបញ្ចាំងមកក្នុងយុគសម័យយើងសព្វថ្ងៃនេះថាៈតើយើងរកបានដែរឬទេ? ទាំងអ្នកឱ្យ!ទាំងអ្នកទទួល? ដូចជាពិបាករកបានណាស់!កម្ររកបានណាស់!ណ្ហើយ! យើងថារកមិនបានតែម្ដងអញ្ចឹងទៅចុះ ដោយយើងត្រូវធ្វើការពិចារណាប្រៀបធៀបមនុស្សពីជំនាន់ព្រះមកជាមួយនឹងមនុស្សជំនាន់យើងសព្វថ្ងៃនេះថាៈមនុស្សពីជំនាន់ព្រះ,កិលេសដែលរួបរិតចិត្តរបស់គេវាស្រាលស្ដើងណាស់! មានប្រហែលជា ២ឬ៣ស្រទាប់ស្ដើងៗតែប៉ុណ្ណោះ, រួចបើគេធ្វើទានអ្វីទៅបដិគ្គាហកៈអ្នកទទួលសុទ្ធតែជាព្រះអរហន្ត អ្នកដែលអស់កិលេសពីខន្ធសន្ដានចិត្តរលីងផងនោះ! បើលោកធ្វើភត្តានុមោទនា!តែ១គាថាឬកន្លះគាថាមកអ្នកឲ្យស្ដាប់ហើយមានចិត្តរិតតែជ្រះថ្លាថែមទៀតនោះ

នោះកិលេសដែលវាស្រាលស្តើងស្រាប់នោះវានឹងជ្រះស្រឡះចេញពីសន្តានចិត្តអស់! ហើយនឹងបានសម្រេចនូវធម៌ជាន់ខ្ពស់ភ្លាមៗ មួយរំពេចឬបើមិនដូច្នោះទេ នឹងបានសម្រេចផលជាក់ស្តែងទាន់ភ្នែកភ្លាមៗយ៉ាងពិតប្រាកដមិនខានឡើយ។ រួចបើប្រៀបធៀបមកជាមួយមនុស្សជំនាន់យើងសព្វថ្ងៃនេះវិញថាព្រះពុទ្ធបរិនិព្វានទៅអស់រយៈពេលជាង២៥៥០ឆ្នាំហើយបើនិយាយពីកិលេសដែលវារួបរឹតចិត្តរបស់យើងមកដល់សព្វថ្ងៃនេះក៏វាជាង២៥៥០ស្រទាប់ម្នាក់ៗអញ្ចឹងដែរ!ម្លោះហើយបើយើងធ្វើទានឬធ្វើបុណ្យអ្វីទៅ ធ្វើម៉េចនឹងបានផលជាក់ស្តែងភ្លាមៗដូចជាមនុស្សកាលពីជំនាន់ព្រះនោះ ?បើយើងទាំងអស់គ្នាទាំងអ្នកឱ្យទាំងអ្នកទទួលសុទ្ធតែមានកិលេសក្រាស់ៗដូចគ្នាក៏ប៉ុន្តែវាជាសំណាងល្អម្យ៉ាងដែរដោយកិលេសវាអត់មានរូបប្រសិនបើកិលេសវាមានរូបវិញលោកអ្នកសប្បុរសទាំងឡាយ! មនុស្សយើងនៅលើពិភពលោក នេះទាំងមូលមានរាប់រយ ពាន់លាននាក់ចុះបើម្នាក់ៗមានកិលេសរាប់ពាន់រាប់ម៉ឺនស្រទាប់គ្រប់ៗគ្នាអញ្ចឹងទៅ តើដុំពិភពលោកទាំងមូលហ្នឹង រកកន្លែងដាក់កិលេសឯណាបាន ? គឺថាដុំពិភពលោកនេះ រកកន្លែងដាក់កិលេសមិនបានទេ!។ ប៉ុន្តែ វាជាសំណាងល្អណាស់! ដែលកិលេសវាអត់មានរូប វាចង់ចូលទៅនៅក្នុងចិត្តរបស់យើងប៉ុន្មានពាន់ ប៉ុន្មានម៉ឺនស្រទាប់ក្នុងម្នាក់ៗ ក៏ចេះតែរកកន្លែងនៅបាន!មិនចង្អៀត ប៉ុន្តែក្រាស់ណាស់ច្រើនណាស់! រួចមានមនុស្សខ្លះកិលេសវារួបរឹតចិត្តជិតឈឹង! ល្ងិតសូន្យសុងតែម្តងក៏មាន,ម្លោះហើយធ្វើម៉េចនឹងធ្វើបុណ្យទានអ្វីទៅឱ្យបានផលជាក់ស្តែងដូចជាមនុស្សកាលពីជំនាន់ព្រះនោះ ?ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយក៏យើងទាំងអស់គ្នាទាំងអ្នកឱ្យទាំងអ្នកទទួលគប្បីខំប្រឹងតស៊ូព្យាយាមតាំងចិត្តប្តូរផ្តាច់ទាំងអស់គ្នា! ដើម្បីប្រព្រឹត្តខ្លួនឱ្យចូលទៅជិតអង្គទាំង៦ប្រការនោះឱ្យបាន បើមិនទាន់បានដល់ទេក៏ឱ្យចូលទៅក្នុងគន្លងផ្លូវនោះដែរ ដើម្បីយើងធ្វើទានទៅឱ្យបានផលច្រើន,

សាធុសប្បុរសទាំងឡាយ!ព្រះធម៌ទេសនាដែលព្រះពុទ្ធទ្រង់សំដែងអំពីទាននេះ មានច្រើនជាអនេក! ហួសនិស្ស័យនឹងពណ៌នាឱ្យសព្វគ្រប់បានដូច្នេះខ្ញុំសូមលើកយកមកសំដែងតែខ្លះៗដើម្បីអស់លោកអ្នកបានពិចារណាដូចតទៅនេះក្នុងព្រះពុទ្ធសាសនារឿងទាននេះបណ្ឌិតលោកសង្គ្រោះចូលក្នុងធម៌ទាំងឡាយច្រើនយ៉ាងណាស់ ដូចជានៅក្នុងបុញ្ញ-កិរិយាវត្ថុ១០យ៉ាងទាននេះជាទី១,ក្នុងទសពិធរាជធម៌ធម៌សម្រាប់អ្នកធ្វើស្តេចឬអ្នកដឹកនាំ១០យ៉ាងក៏មានទាននេះជាទី១, ក្នុងបារមីធម៌១០ក៏មានទានបារមីជាទី១, នៅក្នុងអរិយទ្រព្យ៧ប្រការក៏និយាយអំពីទាននេះជាទ្រព្យដ៏ប្រសើរដែរ! ក្នុងសង្គហធម៌៤ ក៏មានទានជាទី១,នៅក្នុងសប្បុរិសធម៌៥ប្រការ ក៏មាន **សទ្ធច្ចំ ទានំ ទេតិ** ការឱ្យទានដោយគោរពជាទី១ដែរ,និងក្នុងអនុបុព្វីកថានៃពុទ្ធកិច្ច៥យ៉ាងរបស់ព្រះពុទ្ធក៏ព្រះអង្គសំដែងអំពីទាននេះមុនគេដែរ ទើបទ្រង់សំដែងអំពីសីល, អំពីឋានសួគ៌អំពីទោសនៃកាម, និងអំពីអានិសង្សនៃនេក្ខម្មៈគឺការចេញចាកកាមទៅសាងផ្នួសបួសជាបព្វជិតតាមលំដាប់លំដោយជាបន្តបន្ទាប់ទៅ, គឺសុទ្ធតែនិយាយអំពីទាននេះទាំងអស់!។ ព្រះពុទ្ធទ្រង់ជ្រាបច្បាស់ណាស់ថានិស្ស័យសន្តានចិត្តមនុស្សលោក ភាគច្រើនណាស់ដែលចាប់អារម្មណ៍ខ្លាំងទៅលើតែទ្រព្យសម្បត្តិអ្នកខ្លះសុខចិត្តរស់នៅជាមួយទ្រព្យសម្បត្តិយ៉ាងប្តូរផ្តាច់ដោយគេគិតថាៈ ជីវិតរបស់គេដែលខ្ពង់ខ្ពស់ដោយសារតែទ្រព្យសម្បត្តិតែម៉្យាង ហើយហាក់ដូចជាចង់រស់នៅតែម្នាក់ឯង! ដោយមិនបានគិតដល់ការរស់របស់អ្នកដទៃផងទេ! ឬជួនកាលក៏យកកម្លាំងទ្រព្យសម្បត្តិទៅបៀតបៀនអ្នកដទៃផងក៏មាន!នៅក្នុងព្រះធម៌ទេសនារបស់ព្រះអង្គព្រះពុទ្ធតែងណែនាំមនុស្សឱ្យចេះលះបង់ទ្រព្យសម្បត្តិធ្វើអំណោយដល់មនុស្សដែលគួរធ្វើអំណោយផង មានមនុស្សអ្នកទីទ័ល-ក្រ,ខ្វាក់ខ្វិន,ឬរងគ្រោះដោយគ្រោះថ្នាក់អ្វីៗផ្សេងៗមានភ្លើងឆេះផ្ទះ ឬទឹកជន់លិចភូមិស្រុកជាដើម!។និងព្រះអង្គឱយចិញ្ចឹមមនុស្សដែលត្រូវ

ចិញ្ចឹមមានភរិយានិងបុត្រជាដើម, ព្រះអង្គឱ្យបូជាចំពោះមនុស្សដែល
គួរបូជាមានមាតាបិតាគ្រូអាចារ្យជាដើម! គឺសុទ្ធតែក្នុងការធ្វើទានហ្នឹង
ទាំងអស់,ជាពិសេសជាងនេះទៀតព្រះពុទ្ធទ្រង់ពន្យល់ថាទ្រព្យសម្បត្តិ
គេមិនត្រូវស្រឡាញ់ជាប់ចិត្តឱ្យហួសហេតុពេក ទាល់តែចាយមិនកើត
ឬមិនហ៊ានចាយនោះទេ!ទ្រព្យសម្បត្តិគេមិនត្រូវប្រើជាកម្លាំងសម្រាប់
បៀតបៀនជិះជាន់ សង្កត់សង្កិនអ្នកដទៃនោះទេ! បើយកកម្លាំងទ្រព្យ
ទៅបៀតបៀនអ្នកដទៃនោះបណ្ឌិតលោកពោលថាៈ “ មានបាបច្រើន
ដោយសារតែមានទ្រព្យសម្បត្តិច្រើននោះទៅវិញទេ”រួចជាមនុស្សមិន
ត្រូវគោរពទ្រព្យសម្បត្តិឱ្យទ្រព្យសម្បត្តិធ្វើជាម្ចាស់លើខ្លួនយើងនោះទេ
បំណាច់បានកើតមកជាមនុស្សអ្នកមានទ្រព្យសម្បត្តិច្រើនហើយ គប្បី
បំពេញមុខងាររបស់ខ្លួនជាអ្នកមានទ្រព្យសម្បត្តិច្រើនៗផង គឺថាត្រូវចំ
ណាយទ្រព្យសម្បត្តិដែលជារបស់មិនមានសារប្រយោជន៍ (ជាបរមត្ថ)
ធ្វើឱ្យជារបស់មានសារប្រយោជន៍ឡើងធ្វើឱ្យជាប្រយោជន៍ដល់ខ្លួនឯង
ផង,ដល់អ្នកដទៃផង,ដល់សង្គមជាតិផង,ឬដល់សាសនាផង,និងដល់
ពិភពលោកថែមទៀតផង។និយាយដោយសារុបឡើងវិញ,ព្រះពុទ្ធព្រះ
អង្គមានព្រះអធ្យាស្រ័យចំពោះសេចក្តីសុខទុក្ខរបស់មនុស្សក្នុងជីវិតជា
មនុស្សជាតិនៅលើពិភពលោកនេះដ៏ច្រើនមហិមាព្រះអង្គមានព្រះទ័យ
ករុណាច្រើនពេកណាស់!។ដូច្នេះបានជាអ្នកប្រាជ្ញខាងទស្សនវិជ្ជាបាន
ពោលថាៈ ព្រះពុទ្ធគឺជាព្រះពុទ្ធរបស់មនុស្សជាតិទូទៅទាំងពិភពផែនដី
នេះទាំងមូល!ព្រមទាំងមារព្រហ្ម ព្រះឥន្ទ្រ ទេវតាទាំងអស់ផងមិនមែន
ជាព្រះពុទ្ធរបស់ជនជាតិឥណ្ឌាតែម្នាក់ឯងដាច់មុខនោះទេ!នៃអ្នកប្រាជ្ញ
ខាងទស្សនវិទូលោកពោលអញ្ចឹង!។ព្រះសម្ពុទ្ធទ្រង់តែងត្រាស់សំដែង
ឱ្យអ្នកមានទ្រព្យសម្បត្តិច្រើនៗបរិច្ចាគទ្រព្យសម្បត្តិធ្វើជាទានផង,បាន
ន័យថាៈត្រូវចេះចែករំលែកសេចក្តីសុខដល់មនុស្សផងគ្នាផងរួចត្រូវធ្វើ
ដោយសុទ្ធចិត្តដោយចិត្តមេត្តាពិតៗពីព្រោះការបរិច្ចាគទ្រព្យសម្បត្តិធ្វើ

ជា“ទាន”នេះ គឺជាគុណធម៌ម្យ៉ាងដ៏ប្រសើរបំផុត! ក្នុងការកំចាត់បង់នូវ
មច្ឆរិយកិលេសគឺសេចក្តីកំណាញ់ ឱ្យអស់ពីសន្តានចិត្តបន្តិចម្តងៗនិង
ដែលអាចឈានទៅដល់សេចក្តីស្អាតផូរផង់នៃចិត្តដែលស្ថិតនៅក្នុងផ្លូវ
ឆ្ពោះទៅរកសេចក្តីសុខសន្តិភាពពិតៗគឺសេចក្តីស្ងប់កាយ-ចិត្តនោះឯង
ព្រោះមនុស្សគ្រប់រូប នៅលើពិភពលោកនេះទាំងមូល ក្រោយពីស្លាប់
ទៅពុំមាននរណាម្នាក់អាចយកទ្រព្យសម្បត្តិអ្វីៗទៅជាមួយផងបានទេ
ឡានវិឡាប្រាក់មាសពេជ្រអ្វីទុកចោលទាំងអស់ សូម្បីសំលៀកបំពាក់
ដែលស្លៀកជាប់នឹងខ្លួនហ្នឹង!ក៏មិនអាចយកទៅជាមួយបានផង!មាន
តែសេចក្តីល្អ គឺបុណ្យកុសល ដែលឋិតនៅជិតជាប់នឹងចិត្តវិញ្ញាណ ដ៏
ស្អាតផូរផង់របស់យើងនោះទេទើបអាចនាំបដិសន្ធិវិញ្ញាណរបស់យើង
ឲ្យទៅកើតនៅឯស្ថានសួគ៌សុគតិភពបាន ត្រូវយល់ឱ្យច្បាស់អញ្ចឹង!។
យើងកើតមកជាមនុស្សនេះប្រសើរណាស់មានភព្វសំណាងណាស់រួច
បានកើតមកជួបទាន់ នឹងព្រះពុទ្ធសាសនាទៀតនោះ ពេញហៅចំជា
មហាប្រសើរព្រោះសាសនាព្រះពុទ្ធល្អណាស់!បើយើងបានរៀនសូត្រ
ធម៌ព្រះពុទ្ធ គឺរៀនពីពាក្យរបស់ព្រះពុទ្ធឱ្យបានច្រើន រៀនឱ្យបានដល់
ជម្រៅរបស់ពាក្យនោះៗទៅទើបយើងយល់ទើបយើងឃើញច្បាស់ថា
សាសនាព្រះពុទ្ធល្អមែនល្អណាស់ល្អមិនមានសាសនាដទៃណាប្រៀប
ផ្ទឹមស្មើបានឡើយ! ព្រោះអ្វី? ពីព្រោះថា:សាសនារបស់ព្រះពុទ្ធមាន
ហេតុមានផលច្បាស់លាស់ណាស់សាសនាព្រះពុទ្ធមិនប្រដៅមនុស្ស
ឱ្យជឿតាម,ឱ្យធ្វើតាមទាំងងងឹតងងល់ឬថាទាំងធ្មេចភ្នែកនោះទេ ព្រះ
ពុទ្ធសាសនាមិនប្រដៅមនុស្សឱ្យជឿតាម ឱ្យធ្វើតាមដោយមិនបានពិ-
ចារណា ឱ្យឃើញហេតុ-ផលច្បាស់លាស់ជាមុនសិន! ហើយសឹមជឿ
នោះទេបានន័យថា:ព្រះពុទ្ធប្រដៅមនុស្សថាប្រសិនបើយើងមានសទ្ធា
ជឿលើអ្វីមួយហើយ ត្រូវប្រើបញ្ញា ពិចារណាឱ្យបានយល់ឃើញហេតុ-
ផលច្បាស់លាស់ល្អិតល្អន់ផងទើបត្រឹមត្រូវ។ បើដូច្នេះមុខគួរឱ្យស្តាយ

ណាស់!ចំពោះពួកមនុស្សដែលបានកើតមកជាមនុស្សហើយបានទាន់សាសនាព្រះពុទ្ធហើយ, ហើយបែរជាធ្វើខ្លួនឱ្យស្ថិតនៅឆ្ងាយពីព្រះពុទ្ធ ធ្វើជីវិតរបស់ខ្លួនឱ្យស្ថិតនៅឆ្ងាយពីធម៌របស់ព្រះពុទ្ធទៅវិញនោះ, នោះហើយដែលមុខគួរឱ្យស្តាយណាស់! គួរឱ្យស្តាយជាទីបំផុតនោះ!ព្រោះអ្វី?“ ព្រោះភពកំណើតរបស់មនុស្សនេះជាភពជាកន្លែងសំរាប់កសាងអំពើល្អ! អំពើល្អគ្រប់យ៉ាង” រួច(អំពើអាក្រក់ក៏នៅហ្នឹងដែរ)ហើយអំពើល្អដែលប្រាប់ហេតុ-ផលច្បាស់លាស់នោះមានតែក្នុងព្រះពុទ្ធសាសនាទេ ត្រូវយល់ឱ្យច្បាស់ហើយចាំឱ្យច្បាស់អញ្ចឹង។ខ្ញុំលើកឧទាហរណ៍យ៉ាងខ្លីមកបញ្ជាក់ជូនឲ្យលោកអ្នកស្តាប់បានឃើញហេតុផលច្បាស់លាស់! សូមអ្នកស្តាប់យកចិត្តទុកដាក់សង្កេតពិនិត្យឲ្យមែនទែនព្រោះនេះសុទ្ធតែជា“មេ”ពាក្យជាខ្លឹមរបស់ពាក្យ, ឥឡូវសូមស្តាប់ឲ្យច្បាស់ព្រះពុទ្ធដីកាសំដែងថា“ បើហេតុមាន ទើបផលមាន, បើហេតុល្អ ផលក៏ល្អ, បើ-ហេតុអាក្រក់ ផលក៏អាក្រក់” នេះ!ដែលហៅថាធម៌មានហេតុមានផលច្បាស់លាស់នោះ!គឺវាច្បាស់ចែសអញ្ចឹង!បើហេតុយ៉ាងណា?ផលវាក៏យ៉ាងហ្នុង,ឥឡូវស្តាប់មួយបែបទៀតដោយប្រុងប្រយ័ត្នព្រះពុទ្ធពោលៈ

១- បើនេះមាន នុ៎ះក៏មាន, បាលីថា ឥមស្មឹ សតិ ឥទំ ហោតិ ។
២- បើនេះមិនមាន នុ៎ះក៏មិនមាន, = ឥមស្មឹ អសតិ ឥទំ ន ហោតិ
៣- បើនេះកើតឡើង នុ៎ះក៏កើតឡើង, = ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ
៤- បើនេះរលត់ នុ៎ះក៏រលត់, = ឥមស្ស និរោធា ឥទំ និរុជ្ឈតិ

នែ!នេះហើយដែលហៅថា“ធម៌មានហេតុមានផល”ច្បាស់លាស់នោះគឺវាច្បាស់អញ្ចឹង។រួចធម៌នេះនឹងហៅថា” “បដិច្ចសមុប្បាទធម៌”ក៏បានបាន។សាធុសប្បុរសទាំងឡាយស្តាប់ហើយសូមយកទៅសញ្ជឹងគិតពិចារណាឱ្យបានម៉ត់ចត់ឲ្យបានដឹតដល់មែនទែនទើបយល់សេចក្តីបាន បើគ្រាន់តែស្តាប់ៗ ហើយមិនបានពិចារណាឲ្យបានល្អិតល្អន់ល្អផងទេ នោះមិនអាចយល់ដល់ជម្រៅនៃពាក្យទាំងនេះបានទេ ព្រោះពាក្យទាំង

នេះមានន័យជ្រៅបន្តិចហើយ!។ អស់លោកសាធុសប្បុរសទាំងឡាយ ដែលនិយាយមកដល់ធម៌មានហេតុ មានផលច្បាស់លាស់នេះ ព្រោះ វាជាប់ទាក់ទងនឹងភពកំណើតរបស់មនុស្សនេះជាភពជាស្ថានសម្រាប់ កសាង"ភពស្ថាន"របស់មនុស្សជាភពសម្រាប់កសាង។ ជាមនុស្សនៅ លើដុំពិភពលោកនេះទាំងមូលបើចង់កសាងខ្លួនឱ្យបានកើតទៅជាអ្វី? គឺបើចង់កសាងខ្លួនឲ្យបានកើតជាព្រះពុទ្ធ,ជាព្រះបច្ចេកពុទ្ធ,ជាសាវកៈ ពុទ្ធ,ជាព្រះឥន្ទ្រ,ជាព្រះព្រហ្ម,ជាទេវតា,ឬក៏ជាស្តេចចក្រពត្រាធិរាជលើ ផែនដី,ជាស្តេច,ជាសេដ្ឋី,ជាគហបតី,ជាដើម គឺសុទ្ធតែត្រូវខំកសាងខ្លួន ពីស្ថានរបស់មនុស្សនេះទៅទាំងអស់,មិនអាចទៅកសាងពីកន្លែងណា ក្រៅពីស្ថានរបស់មនុស្សនេះបានសោះឡើយ!។ មានសំនួរថា:ចុះការ កសាងខ្លួនឱ្យបានមុខដំណែងទាំងអស់ហ្នឹង! តើត្រូវកសាង យ៉ាងម៉េច ទៅ?តើបានមកពីអ្វី?កសាងអ្វី? ចម្លើយ: ដើម្បីបានមុខដំណែងទាំង អស់ហ្នុងគឺបានមកពីការឱ្យទានបានមកពីការធ្វើទានបានមកពីការខំបំ ពេញទាននោះឯងដែលហៅថា"ទានបារមី"នោះ!ពីព្រោះថាសូម្បីព្រះ ពុទ្ធគ្រប់ព្រះអង្គមុននឹងបានត្រាស់ដឹងជាព្រះពុទ្ធកាលនៅជាព្រះពោធិ សត្វនៅឡើយ គឺព្រះអង្គសុទ្ធតែបានបំពេញនូវទានបារមី នេះអស់ជា ច្រើន"អសង្ខៃយ្យ"ជាតិមកហើយ,ហើយច្រើនតែជា"បរមត្ថបារមីទាន "ផង!។ បរមត្ថបារមីទានគឺជាទានដែលមិនមានមនុស្ស ឬទេវតាឥន្ទ្រ, ព្រហ្មណាធ្វើគ្រាប់តាមព្រះអង្គកើតឡើយ!ឈ្មោះថា: "អជ្ឈត្តិកទាន" ទានខាងក្នុងជាមហាទាន!មហាអស្ចារ្យទាន!។ ដោយសារមហាផលា និសង្សនៃបរមត្ថបារមីទាន ជាទានដ៏អស្ចារ្យ!របស់ព្រះពុទ្ធនេះ ហើយ ដែលបណ្តាលឱ្យកើតមានជា រស្មី៦ពណ៌ ផ្សាយចេញអំពីព្រះវរកាយ របស់ព្រះពុទ្ធអង្គនោះគឺថា:ទី១- រស្មីពណ៌ ខៀវ កាលទ្រង់សោយព្រះ ជាតិជាព្រះបាទស្រីភិរាស្ត្រ ពេលនោះព្រះឥន្ទ្រាធិរាជបាននិមិតខ្លួនធ្វើ ជាព្រាហ្មណ៍ម្នាក់ទៅសុំព្រះនេត្រព្រះអង្គទាំងគូ ព្រះអង្គ! ក៏ឆ្កៀលព្រះ

នេត្រទាំងពីរឱ្យទៅឥន្ទព្រាហ្មណ៍។ ទី២-រស្មីពណ៌ លឿង កាលទ្រង់សោយព្រះជាតិជាវិរិយបណ្ឌិតព្រះឥន្ទនិមិតខ្លួនជាយក្សធ្វើជាងមាសកសាងព្រះពុទ្ធរូបរួចខ្វះមាសបិទ,វិរិយបណ្ឌិតបានអារសាច់របស់ខ្លួនឲ្យជាងមាសដំផៃធ្វើជាមាសបិទព្រះពុទ្ធរូប ។ ទី៣-រស្មីពណ៌ក្រហម កាលទ្រង់សោយព្រះជាតិជាបទុមមានពកាលនោះមាតាព្រះអង្គត្រូវសត្វពស់មានពិសខាំ មានព បានពុះទ្រូងលូកយកបេះដូង មកធ្វើថ្នាំព្យាបាលមាតាឱ្យមានជីវិត។ទី៤- រស្មីពណ៌ស កាលទ្រង់សោយព្រះជាតិជាព្រះបាទវេស្សន្តរបានប្រទានដំរីសសុទ្ធជាមង្គលសម្រាប់រាជ្យទៅឲ្យពួកព្រាហ្មណ៍កាលិង្គរដ្ឋ រួចអ្នកនគរគេខឹងបានឱ្យបំបរបង់ព្រះអង្គស្តេចទៅគង់នៅបំពេញតបៈធម៌ឯភ្នំគិរីវង្កត់ឯណោះ។ ទី៥- រស្មីពណ៌ហង្សបាទ( ពណ៌ដូចជើងសត្វហង្ស )កាលទ្រង់សោយព្រះជាតិជាវិទ្យាធរពេលនោះមាតារបស់ព្រះអង្គត្រូវយក្សចាប់យកទៅព្រះអង្គបានអារសាច់របស់ព្រះអង្គ ឲ្យយក្សស៊ីជំនួសជីវិតមាតា!។ ទី៦- រស្មីពណ៌ផ្លេក កាលសោយព្រះជាតិជាទន្សាយឈ្មោះសោមបណ្ឌិត,ព្រះឥន្ទនិមិត្តខ្លួនជាព្រាហ្មណ៍ចាស់អត់អាហារបរិភោគទៅសុំទាន,សោមបណ្ឌិតគ្មានរបស់អ្វីឲ្យ ក៏រលាស់ខ្លួន៧ដងក្រែងមានសត្វល្អិតៗ!ជាប់នឹងខ្លួន រួចលោតចូលទៅក្នុងភ្នក់ភ្លើងចំអិនសាច់របស់ខ្លួនឲ្យឥន្ទព្រា-ហ្មណ៍បរិភោគ!។ នែ!ទាំងអស់ហ្នឹង! តើមានមនុស្សទេវតាឥន្ទព្រហ្មណាធ្វើបានដូចព្រះអង្គ ?ដូច្នេះឯងបានជាហៅថា“បរមត្ថបារមីទាន” នោះ,គឺជាទានដ៏អស្ចារ្យណាស់ដែលពុំមានអ្នកដទៃណាធ្វើតាមកើតឡើយ!។ អាស្រ័យហេតុដ៏អស្ចារ្យនេះហើយ ទើបបានជាសម្តេចព្រះសង្ឃរាជ.ជួន-ណាត. ព្រះអង្គបាននិពន្ធជាបទ( ភ្លេង )សំរាប់ឲ្យសូធ្យលើកទង់និងដាក់ទង់ជ័យព្រះពុទ្ធសាសនានេះ ទុកតមកៈដូចតទៅ!

## <u>បទលើកទង់</u>

ក្រុមយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថា ព្រះពុទ្ធជិនស្រី

ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មី ទាំងប្រាំមួយពណ៌។
ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងរិទ្ធិរុង ប្រសើរបវរ
ឆ្អៀវឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ ស្រស់ល្អសោភា
កំណើតនៃព្រះរស្មី កើតដោយបារមី ទាននៃភគវ៉ា
ធ្វើទានឥតមានរុញរា កាលដែលនៅជា ព្រះពោធិសត្វ
រស្មីពណ៌ខៀវនោះណា កាលឆ្កៀលនេត្រា ទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍បាត់ កាលនៅជាក្សត្រ នាមស្រីភិរាស្រ្ត
រស្មីពណលឿងភ្លឺថ្លា កាលដែលទ្រង់អារ សាច់ផៃធ្វើមាស
បិទពុទ្ធរូបភ្លឺឱភាស ព្រះឥន្ទជាងមាស ទ្រង់វ័យបណ្ឌិត
រស្មីក្រហមនោះណា កាលដែលមាតា ពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត(អានបូទុំ) កាត់បេះដូងបិទ ធ្វើថ្នាំមាតា
រស្មីពណ៌ស សុទ្ធសាធ កាលដែលព្រះបាទ វេស្សន្តរក្សត្រា
ឲ្យទានដំរីស សោភា ដល់ព្រាហ្មណ៍ ប្រាថ្នាយកពោធិញ្ញាណ
រស្មីពណ៌ដូចជើងហង្ស កាលមាតាទ្រង់ យក្សឆក់យកបាន
វិទ្យាធរ អារសាច់ប្រាណ ឱ្យយក្សសាមាន្យ ស៊ីប្តូរជីវិត
រស្មីពណ៌ផ្លេកពណ្ណរាយ កើតជាទន្សាយ ឈ្មោះសោមបណ្ឌិត
ឲ្យទានសាច់ ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិត ថាអត់អាហារ
រស្មីខៀវ-លឿង-ក្រហម ស-ហង្សបាទ ព្រម ភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ទាំងចាស់-កុមារចូរចាំទុកអើយ!(អានកឺយ)៕

អស់លោកសាធុសប្បុរសទាំងឡាយ!ទាំងព្រះឥន្ទព្រះព្រហ្មទេវតាទាំងស្តេចចក្រពត្រាធិរាជលើផែនដីជាដើមដែលបានដំណែងទាំងអស់នេះសុទ្ធតែបានបំពេញទានដ៏ច្រើន! រាប់ជាតិជាអនេកមកហើយ ហើយក៏ច្រើនតែជាទានដ៏ឧក្រឹដ្ឋផង ទើបបានទៅកើតជាអស់ហ្នឹងនោះ!ពុំមានព្រះឥន្ទណាដែលមិនបានបំពេញទាន! ហើយបានទៅកើតជាព្រះឥន្ទនោះទេ! អត់ដែលមានទេ! អត់ទេ!។ដូច្នេះសូមអស់លោកអ្នកធ្វើទាន

ទាំងឡាយ មេត្តាតាំងចិត្តគោរពកុសលថ្នាក់ទានរបស់ខ្លួន ឲ្យបានល្អប្រសើរ! ទោះបីទាននោះយើងធ្វើតិចក្តីច្រើនក្តីក៏ត្រូវតែតាំងចិត្តគោរពឲ្យបានល្អប្រសើរជានិច្ចទើបបានផលច្រើន! ព្រះធម៌ ស្តីពី ទានចប់៕